ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

បេឡាជាតិរបបសន្តិសុខសង្គម

លេខ : ៧៥/១៦ ប.ស.ស

# សេចក្តីជូនដំណឹង

បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) សូមជម្រាបជូនសមាជិក ប.ស.ស ទាំងអស់ដែលបានចុះបញ្ជិកា និងបង់ភាគទាន សម្រាប់របបសន្តិសុខសង្គមផ្នែកថែទាំសុខភាពជ្រាបថា៖ នៅពេលសមាជិកទាំងអស់មានបញ្ហាសុខភាពត្រូវទៅទទួលសេវាព្យាបាល និងថែទាំវេជ្ជសាស្ត្រនៅមណ្ឌលសុខភាព មន្ទីរពេទ្យ មន្ទីរសម្រាកព្យាបាល និងមន្ទីរពហុព្យាបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស ចាំបាច់ត្រូវបង្ហាញប័ណ្ណសមាជិក(កាតសមាជិក) ដែលផ្តល់ដោយ ប.ស.ស ឬអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរទៅភ្នាក់ងារ ប.ស.ស ឬមន្ត្រីរបស់មូលដ្ឋានសុខាភិបាលទាំងនោះ សមាជិកទាំងអស់មិនត្រូវបង់ប្រាក់លើថ្លៃសេវាអ្វីទាំងអស់ លើកលែងតែឱសថក្រៅពីបញ្ជីឱសថសារវន្ត ដូចមានចែងក្នុង ប្រកាសលេខ ២៣៨ កប/ប្រក ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៦ ស្តីពីការកំណត់បញ្ជីជំងឺរ៉ាំរ៉ៃនៅក្នុងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ ក្នុងករណីមិនបានអនុវត្តតាមការណែនាំខាងលើនោះទេ សមាជិកទាំងអស់ត្រូវប្រឈមនឹងការបង់ប្រាក់ថ្លៃសេវាព្យាបាល និងថែទាំវេជ្ជសាស្ត្រ ដែលបានប្រើប្រាស់ជូនមូលដ្ឋានសុខាភិបាល។

អាស្រ័យហេតុនេះសូម សមាជិក ប.ស.ស ទាំងអស់ជ្រាបជាពត៌មាន។

សូម សមាជិក ប.ស.ស ទាំងអស់ទទួលនូវការរាប់អានពីខ្ញុំ។

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៦

លេខទូរស័ព្ទទំនាក់ទំនង៖

-០៧៨៣៨៣៨៨៧/០៩៨៣៨៣៨៤៣

-០១២៥៦៧៥១៤/០២៣៨៨០៤១៦

-០២៣៨៨២៤៣៤/០២៣៨៨១១៧៦

អាសយដ្ឋានអគារលេខ ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ

ទូរស័ព្ទ: ០២៣-៨៨ ២៤ ៣៤ . ០២៣ ៨៨ ១០ ១៥ ០២៣-៨៨ ១០ ១៦ . ០២៣ ៨៨ ០៤ ១៧

ទូរសារ : ០២៣ ៨៨ ២៦ ២៣ . ប្រអប់សំបុត្រ P.O.Box 70

Website : www.nssf.gov.kh